# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៧៦ ប្រក. កសក

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
14/01/2013
Nº. 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D. Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣)២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351 / 211 352, Fax (855) 23-217 320

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់នូវនីតិវិធីសម្រាប់ការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅកំណត់នូវនីតិវិធីនិងគោលការណ៍រួម សម្រាប់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តនៅក្នុងប្រតិបត្តិការអធិការកិច្ច និងការចាត់វិធានការជំរុញការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការធ្វើអធិការកិច្ច និងរាល់ប្រតិបត្តិការជំរុញការអនុវត្តច្បាប់លើគ្រប់គ្រឹះស្ថាន ឬសកម្មភាពដែលពាក់ព័ន្ធនឹងថ្នាំកសិកម្មនិងជីកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## អង្គភាពមានសមត្ថកិច្ច និងមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

**ប្រការ ៤.-**

នាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអង្គភាពមានសមត្ថកិច្ចធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យនីតិកម្មកសិកម្មនៃមន្ទីរកសិកម្មរាជធានី ខេត្ត ជាអង្គភាពមានសមត្ថកិច្ចធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៅក្នុងដែនដីសាមី។

**ប្រការ ៥.-**

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មត្រូវបានផ្តល់នីតិសម្បទា ជាមន្ត្រីនគរបាលយុត្តិធម៌ ឬជាភ្នាក់ងារនគរបាលយុត្តិធម៌ នៅក្នុងការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ដោយអនុលោមតាមប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៦.-**

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម មានភារកិច្ចនិងសិទ្ធិដូចខាងក្រោម៖

- ធ្វើការត្រួតពិនិត្យដើមគ្រាលើថ្នាំកសិកម្មនិងជីកសិកម្មនៅមុនពេលផ្ដល់សុពលភាព ផ្គត់ផ្គង់ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- តាមដាន ស្រាវជ្រាវ និងត្រួតពិនិត្យជាប្រចាំលើរាល់សកម្មភាពនៅគ្រប់គ្រឹះស្ថានពាក់ព័ន្ធនឹងពាណិជ្ជកម្មថ្នាំកសិកម្មនិងជីកសិកម្មគ្រប់ប្រភេទ
- ត្រួតពិនិត្យការដឹកជញ្ជូនថ្នាំកសិកម្មនិងជីកសិកម្មគ្រប់ប្រភេទ
- តម្រូវឲ្យពាណិជ្ជករថ្នាំកសិកម្មនិងជីកសិកម្មផ្ដល់ព័ត៌មាន និងបង្ហាញលិខិតអនុញ្ញាត វិញ្ញាបនបត្របញ្ជាក់បញ្ជិកា ឬឯកសារដែលពាក់ព័ន្ធក្នុងសកម្មភាពពាណិជ្ជកម្មរបស់ខ្លួន
- ចាត់វិធានការដោយអនុលោមតាមសេចក្ដីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការហាមឃាត់ជាបណ្ដោះអាសន្នចំពោះការផ្គត់ផ្គង់ចែកចាយ ឬការចរាចរលើទីផ្សារនូវប្រភេទថ្នាំកសិកម្មនិងជីកសិកម្មទាំងឡាយណា ដែលក្រសួងបានស្រាវជ្រាវឃើញភស្ដុតាងបង្កហានិភ័យក្នុងផលិតកម្មកសិកម្ម ឬបង្កគ្រោះថ្នាក់ចំពោះមនុស្ស សត្វ និងបរិស្ថាន ឬដែលត្រូវបានចាត់ថ្នាក់ថ្មីជាសារធាតុគ្រោះថ្នាក់ដោយអនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានចូលរួម
- ដកយកសំណាកថ្នាំកសិកម្មឬជីកសិកម្មដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ និងការធ្វើវិភាគផ្ទៀងផ្ទាត់បមាណីយ
- ដកហូតជាបណ្ដោះអាសន្ននូវលិខិតអនុញ្ញាត វិញ្ញាបនបត្របញ្ជាក់បញ្ជិកា ឬឯកសារដែលពាក់ព័ន្ធ ក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- ចាប់យកវត្ថុតាងនិងបិទស្លាកបោះត្រាលើវត្ថុតាង
- បញ្ឈប់សកម្មភាពណាមួយដែលរារាំងដល់ដំណើរការអធិការកិច្ច
- ធ្វើកំណត់ហេតុត្រួតពិនិត្យកន្លែងកើតហេតុ នៅរាល់ពេលធ្វើប្រតិបត្តិការអធិការកិច្ចនិងបំពេញសំណុំបែបបទផ្សេងទៀត ដោយអនុលោមតាមគំរូសំណុំបែបបទប្រើប្រាស់ក្នុងការត្រួតពិនិត្យនិងដោះស្រាយបទល្មើសពាក់ព័ន្ធនឹងថ្នាំកសិកម្មនិងជីកសិកម្ម
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៧.-**

នៅក្នុងប្រតិបត្តិការអធិការកិច្ច មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចមិនត្រូវ៖

- ជៀតជ្រែកនៅក្នុងដំណើរការឬប្រតិបត្តិការពាណិជ្ជកម្មរបស់ប្រតិបត្តិករថ្នាំកសិកម្ម ឬជីកសិកម្មឡើយ

- បង្កឲ្យមានការប៉ះពាល់ដល់ដំណើរការឬប្រតិបត្តិការពាណិជ្ជកម្មរបស់ប្រតិបត្តិករថ្នាំកសិកម្មឬជីកសិកម្ម ដែលបណ្តាលមកពីសកម្មភាពមិនអនុលោមតាមច្បាប់និងនីតិវិធីជាធរមានណាមួយ នៅក្នុងប្រតិបត្តិការអធិការកិច្ចរបស់ខ្លួន

- បញ្ចេញជាសាធារណៈនូវព័ត៌មានសម្ងាត់ដែលពាក់ព័ន្ធនឹងបច្ចេកទេសក្នុងមុខរបរ ឬការធ្វើពាណិជ្ជកម្មថ្នាំកសិកម្មឬជីកសិកម្មរបស់ប្រតិបត្តិករ ដែលទទួលបានពីការធ្វើអធិការកិច្ចថ្នាំកសិកម្មឬជីកសិកម្ម។

## ជំពូកទី ៣
## សិទ្ធិនិងភារកិច្ចរបស់ពាណិជ្ជករឬប្រតិបត្តិករ ថ្នាំកសិកម្មនិងជីកសិកម្ម

**ប្រការ ៨.–**

នៅពេលមានប្រតិបត្តិការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម អ្នកគ្រប់គ្រងគ្រឹះស្ថានឬប្រតិបត្តិករថ្នាំកសិកម្មឬជីកសិកម្ម មានសិទ្ធិនិងភារកិច្ចដូចខាងក្រោម៖

១. អាចស្នើសុំមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច បង្ហាញលិខិតបញ្ជាបេសកកម្ម។

២. ត្រូវអនុញ្ញាតឲ្យមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ដើម្បីចូលត្រួតពិនិត្យនិងផ្តល់កិច្ចសហការក្នុងការធ្វើអធិការកិច្ច ដូចមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

៣. ត្រូវចូលរួមជានិច្ចជាមួយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម នៅពេល ធ្វើអធិការកិច្ចក្នុងគ្រឹះស្ថានថ្នាំកសិកម្មឬជីកសិកម្មរបស់ខ្លួន។

៤. ត្រូវឆ្លើយបំភ្លឺ ពន្យល់ ផ្តល់ព័ត៌មាននិងឯកសារ ឬផ្តល់សេចក្តីអះអាងពាក់ព័ន្ធនឹងការគោរពនិងអនុវត្តច្បាប់ក្នុងប្រតិបត្តិការពាណិជ្ជកម្មថ្នាំកសិកម្មឬជីកសិកម្មរបស់ខ្លួន ប្រកបដោយសីលធម៌ សុចរិតភាព និងការទទួលខុសត្រូវ។

៥. ត្រូវបំពេញឬឆ្លើយតបនឹងបញ្ជីសំណួររបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម និងត្រូវផ្តល់សំណាកថ្នាំកសិកម្មឬជីកសិកម្ម ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យនិងការធ្វើវិភាគផ្ទៀងផ្ទាត់បមាណីយ។

៦- ស្នើសុំឲ្យមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មកត់ត្រានូវរាល់ការឆ្លើយតបឬសេចក្ដីអះអាងទាំងនោះនៅក្នុងកំណត់ហេតុត្រួតពិនិត្យ និងមានសិទ្ធិទទួលបាននូវកំណត់ហេតុ ឬរបាយការណ៍លទ្ធផលនៃការធ្វើអធិការកិច្ច។

៧- ត្រូវធ្វើការកែតម្រូវចំពោះភាពបដិលោមពីការតម្រូវបមាណីយបច្ចេកទេស និងនីតិវិធីអនុវត្តនៅក្នុងប្រតិបត្តិការពាណិជ្ជកម្មពាក់ព័ន្ធថ្នាំកសិកម្មនិងជីកសិកម្ម។

៨- អាចស្នើសុំមិនឲ្យបញ្ចេញឬផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានសម្ងាត់ដែលពាក់ព័ន្ធនឹងបច្ចេកទេសក្នុងមុខរបរឬប្រតិបត្តិការថ្នាំកសិកម្មឬជីកសិកម្មរបស់ខ្លួន។

៩- អាចធ្វើការជំទាស់ឬការតវ៉ាចំពោះសកម្មភាពមិនស្របច្បាប់ណាមួយ ដែលប្រព្រឹត្តដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម។

១០- ត្រូវបំពេញកាតព្វកិច្ចផ្សេងទៀតក្នុងក្របខ័ណ្ឌនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មឬជីកសិកម្ម។

**ប្រការ ៩.-**

អ្នកគ្រប់គ្រងគ្រឹះស្ថានឬប្រតិបត្តិករថ្នាំកសិកម្មឬជីកសិកម្ម ត្រូវទទួលបន្ទុកក្នុងការចំណាយលើសំណាក និងសេវាកម្មធ្វើវិភាគសំណាកថ្នាំកសិកម្មឬជីកសិកម្ម ការចំណាយក្នុងការលើកដាក់ ការដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោលវត្ថុតាងល្មើសពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្ម នៅក្នុងដំណើរការអនុវត្តច្បាប់។

ក្នុងករណីអត្តសញ្ញាណម្ចាស់វត្ថុតាងនៃបទល្មើសមិនត្រូវបានស្គាល់ ការចំណាយនៅក្នុងដំណើរការអនុវត្តច្បាប់គឺជាបន្ទុករបស់រដ្ឋ។

## ជំពូកទី ៤
## នីតិវិធីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

**ប្រការ ១០.-**

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម មានសិទ្ធិធ្វើអធិការកិច្ចតាមកាលកំណត់ ឬមិនតាមកាលកំណត់ ដោយមានការជូនដំណឹងជាមុន ឬដោយពុំមានការជូនដំណឹងជាមុន ដល់អ្នកគ្រប់គ្រងគ្រឹះស្ថានឬប្រតិបត្តិករថ្នាំកសិកម្មឬជីកសិកម្ម។

ក្នុងករណីធ្វើអធិការកិច្ចដោយមានការជូនដំណឹងជាមុន សេចក្ដីជូនដំណឹងផ្លូវការត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវចុះហត្ថលេខាដោយប្រធានអង្គភាពមានសមត្ថកិច្ចធ្វើអធិការកិច្ចសាមី និងត្រូវជូនដំណឹងដល់អ្នកគ្រប់គ្រងគ្រឹះស្ថានឬប្រតិបត្តិករថ្នាំកសិកម្មឬជីកសិកម្ម ដោយរក្សាទុក

ពេលវេលាសមស្របសម្រាប់អ្នកគ្រប់គ្រងគ្រឹះស្ថានឬប្រតិបត្តិករថ្នាំកសិកម្មឬជីកសិកម្មនោះ ត្រៀមលក្ខណៈសម្រាប់ការត្រួតពិនិត្យ។ សេចក្តីជូនដំណឹងផ្លូវការនេះត្រូវធ្វើជូនជាមុន ឬអាចផ្តល់ព័ត៌មានជាមុនដោយផ្ទាល់មាត់ដល់អ្នកគ្រប់គ្រងគ្រឹះស្ថានឬប្រតិបត្តិករដែលត្រូវធ្វើអធិការកិច្ច នៅក្នុងរយៈពេលមិនតិចជាង៥(ប្រាំ)ថ្ងៃមុនថ្ងៃធ្វើអធិការកិច្ច។

ការធ្វើអធិការកិច្ចដោយពុំមានការជូនដំណឹងជាមុន ត្រូវអនុវត្តចំពោះតែ៖

១- ករណីស្រាវជ្រាវឃើញបទល្មើសជាក់ស្តែងពាក់ព័ន្ធនឹងថ្នាំកសិកម្មនិងជីកសិកម្ម។

២- ករណីត្រួតពិនិត្យដើមគ្រាដែលបានធ្វើប្រតិវេទន៍ដោយប្រតិបត្តិករនាំចូលនាំចេញ លាយផ្សំ វេចខ្ចប់ជាថ្មីថ្នាំកសិកម្មឬជីកសិកម្ម នៅមុនពេលផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ។

៣- ករណីអធិការកិច្ចដែលត្រូវឆ្លើយតបចំពោះបណ្តឹងតវ៉ា ឬការធ្វើអធិការកិច្ចចំពោះគ្រោះថ្នាក់ជាយថាហេតុណាមួយ ដែលបង្កឡើងដោយឧបទ្ទវហេតុណាមួយពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្ម។

**ប្រការ ១១.-**

នៅរាល់ពេលធ្វើអធិការកិច្ច មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចត្រូវមានលិខិតបញ្ជាបេសកកម្ម និងត្រូវស្លៀកពាក់ឯកសណ្ឋាន ដែលមានសញ្ញាសម្គាល់និងសញ្ញាស័ក្តិត្រឹមត្រូវ។

គំរូលិខិតបញ្ជាបេសកកម្មនិងគំរូសេចក្តីជូនដំណឹង ស្តីពីការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

**ប្រការ ១២.-**

នៅក្នុងប្រតិបត្តិការអធិការកិច្ច មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចត្រូវអនុវត្តនីតិវិធីតាមដំណាក់កាលដូចខាងក្រោម៖

**១- នីតិវិធីក្នុងដំណាក់កាលត្រៀមអធិការកិច្ច**

នៅមុនពេលចុះប្រតិបត្តិការធ្វើអធិការកិច្ច មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវត្រៀមលក្ខណៈដូចខាងក្រោម៖

- ត្រូវត្រៀមយកជាប់ជាមួយនូវឯកសាររួមមាន ច្បាប់ បទដ្ឋានគតិយុត្តពាក់ព័ន្ធ បញ្ជីសំណួរ សំណុំបែបបទដែលត្រូវប្រើប្រាស់ក្នុងការអនុវត្តច្បាប់ ស្ថិតិបញ្ជិកាថ្នាំកសិកម្មឬជីកសិកម្ម ស្ថិតិក្រុមហ៊ុនឬគ្រឹះស្ថានធ្វើពាណិជ្ជកម្មថ្នាំកសិកម្មឬជីកសិកម្ម និងឯកសារចាំបាច់ផ្សេងទៀត

- ត្រូវទំនាក់ទំនង និងសហការជាមួយមន្ត្រីឬអង្គភាពអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច នៅក្នុងមូលដ្ឋានសាមី

- ក្នុងករណីចាំបាច់ ត្រូវជូនដំណឹងឬទំនាក់ទំនងជាមុន ជាមួយអាជ្ញាធរដែនដី ដែលត្រូវចុះធ្វើប្រតិបត្តិការ ដើម្បីស្នើសុំកិច្ចសហការ។

**២- នីតិវិធីក្នុងដំណាក់កាលចាប់ផ្ដើមអធិការកិច្ច**

នៅពេលចូលដល់ទីតាំងគ្រឹះស្ថានថ្នាំកសិកម្មឬជីកសិកម្ម ឬនៅទីកន្លែងកើតមានបទល្មើស ឬកើតមានគ្រោះថ្នាក់ដោយថាហេតុណាមួយដែលពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្ម មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវបង្ហាញលិខិតបញ្ជាបេសកកម្ម ត្រូវអានខ្លឹមសារលិខិតបញ្ជាបេសកកម្ម និងត្រូវពន្យល់ឲ្យបានច្បាស់លាស់ពីគោលបំណង ក្របខ័ណ្ឌ និងវិសាលភាពនៃការធ្វើអធិការកិច្ចរបស់ខ្លួន ស្របតាមនីតិវិធីនិងបទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធជាធរមាន។

**៣- នីតិវិធីក្នុងដំណាក់កាលត្រួតពិនិត្យជាក់ស្ដែង**

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

- តម្រូវឲ្យអ្នកគ្រប់គ្រងគ្រឹះស្ថានថ្នាំកសិកម្មឬជីកសិកម្ម បង្ហាញនូវសៀវភៅកំណត់ត្រាពាណិជ្ជកម្ម និងបង្ហាញនូវលិខិតអនុញ្ញាតឬវិញ្ញាបនបត្រដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ខ្លួន

- តម្រូវឲ្យអ្នកគ្រប់គ្រងគ្រឹះស្ថានថ្នាំកសិកម្មឬជីកសិកម្ម ឆ្លើយប្រាប់ពីប្រភពថ្នាំកសិកម្មឬជីកសិកម្ម បង្ហាញនូវវិក្កយបត្រឬឯកសារសក្ខីបត្រប្រភពដើមនៃថ្នាំកសិកម្មឬជីកសិកម្ម ដែលធ្វើប្រតិបត្តិការពាណិជ្ជកម្ម ធ្វើសន្និធិ ឬតាំងលក់ ដោយត្រូវប្រើបញ្ជីសំណួរដែលបានរៀបចំជាមុនសម្រាប់ប្រើប្រាស់ក្នុងការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

- ត្រូវត្រួតពិនិត្យលើការអនុវត្តច្បាប់ បច្ចេកទេស និងការតម្រូវបមាណីយ លើផលិតផលថ្នាំកសិកម្មឬជីកសិកម្ម ដកយកសំណាកសម្រាប់ធ្វើវិភាគ ថតរូបសកម្មភាពធ្វើអធិការកិច្ចរបស់ខ្លួន និងត្រូវប្រមូលឬថតចម្លងឯកសារពាក់ព័ន្ធដែលចាំបាច់ ដើម្បីទុកជាភស្តុតាងនៃសំណុំរឿងបទល្មើស ឬភ្ជាប់ក្នុងរបាយការណ៍ជូនប្រធានអង្គភាពមានសមត្ថកិច្ចសាមី

- ត្រូវចាត់វិធានការតាមច្បាប់ចំពោះជនប្រព្រឹត្តបទល្មើស ស្របតាមវិធានការពាក់ព័ន្ធដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ។

**៤- នីតិវិធីក្នុងដំណាក់កាលបញ្ចប់អធិការកិច្ច**

នៅពេលបញ្ចប់ការត្រួតពិនិត្យជាក់ស្ដែង មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

- បូកសរុបបញ្ចប់លទ្ធផលនៃការធ្វើអធិការកិច្ច រៀបចំបណ្ដាកំណត់ហេតុ ព្រមទាំងបំពេញសំណុំបែបបទពាក់ព័ន្ធផ្សេងទៀត តាមករណីជាក់ស្ដែង

- បង្ហាញដល់ម្ចាស់គ្រឹះស្ថាន នូវកំហុសរបស់ខ្លួនក្នុងការធ្វើប្រតិបត្តិការពាក់ព័ន្ធថ្នាំកសិកម្មឬជីកសិកម្មដែលបានត្រួតពិនិត្យឃើញ ដោយត្រូវណែនាំដល់ម្ចាស់គ្រឹះស្ថានឲ្យអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ នីតិវិធី និងបទបញ្ជាពាក់ព័ន្ធជាធរមាន

- ត្រូវចុះហត្ថលេខាលើកំណត់ហេតុ និងលើសំណុំបែបបទផ្សេងទៀត ដោយត្រូវអានកំណត់ហេតុនោះឲ្យដល់អ្នកគ្រប់គ្រងគ្រឹះស្ថានឬប្រតិបត្តិករថ្នាំកសិកម្មឬជីកសិកម្មសាមីបានស្តាប់ឮដោយផ្ទាល់ ដើម្បីឲ្យបុគ្គលនោះយល់ព្រមចុះហត្ថលេខាលើកំណត់ហេតុឬសំណុំបែបបទនៃបទល្មើសនោះ។

**៥- នីតិវិធីក្នុងដំណាក់កាលក្រោយពេលបញ្ចប់អធិការកិច្ច**

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវធ្វើរបាយការណ៍អធិការកិច្ចជាលាយលក្ខណ៍អក្សរជូនប្រធានអង្គភាពមានសមត្ថកិច្ចសាមី ក្នុងរយៈពេលយ៉ាងយូរ១០ (ដប់)ថ្ងៃ ដោយគិតចាប់ពីថ្ងៃបញ្ចប់ការងារអធិការកិច្ចថ្នាំកសិកម្មឬជីកសិកម្ម។ មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច អាចធ្វើរបាយការណ៍ផ្ទាល់មាត់ជាមុនតាមការតម្រូវរបស់ប្រធានអង្គភាពមានសមត្ថកិច្ចធ្វើអធិការកិច្ចសាមី ក្នុងករណីចាំបាច់។

របាយការណ៍អធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវមានខ្លឹមសារអប្បបរមា ស្របតាមមាតិកាដូចខាងក្រោម៖

- យោងលិខិតបញ្ជាបេសកកម្ម ដែលបញ្ជាក់សមាសភាពក្រុមមន្ត្រីអធិការកិច្ច
- សមាសភាពអ្នកចូលរួមដទៃទៀត
- គោលបំណងនៃការធ្វើអធិការកិច្ច
- ទីកន្លែងធ្វើអធិការកិច្ច
- លទ្ធផលនៃការធ្វើអធិការកិច្ច និងការរកឃើញបទល្មើស
- វិធានការរបស់មន្ត្រីអធិការកិច្ចនៅនឹងកន្លែងកើតហេតុ
- ការចងក្រងសំណុំរឿង
- ការស្នើសុំវិធានការបន្តពីប្រធានអង្គភាពមានសមត្ថកិច្ចសាមី ឬស្នើសុំសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី ឬរបស់ប្រធានមន្ទីរកសិកម្មសាមីចំពោះករណីបទល្មើសដែលរកឃើញ
- ត្រូវភ្ជាប់ឯកសារពាក់ព័ន្ធ រូបថតសកម្មភាព ឬភស្តុតាងផ្សេងទៀតជាចាំបាច់។

**ប្រការ ១៣.-**

ការធ្វើអធិការកិច្ចបន្តជាថ្មីម្តងទៀត ត្រូវបានអនុវត្តដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មដោយពុំចាំបាច់មានការជូនដំណឹងជាមុន ឬការចុះត្រួតពិនិត្យតែលើការអនុវត្តរបស់ ប្រតិបត្តិករដែលបានទទួលការព្រមាន ការឲ្យកែតម្រូវ ឬការដាក់ទណ្ឌកម្មផ្សេងទៀត ដើម្បីធានានូវការអនុវត្តត្រឹមត្រូវតាមវិធានការដែលបានដាក់ចេញនៅពេលធ្វើអធិការកិច្ចលើកមុន។

**ប្រការ ១៤.-**

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវគ្រប់គ្រងឯកសារនៃករណីសំណុំរឿងបទល្មើសនីមួយៗ ដោយត្រូវរៀបចំនិងកត់ត្រានៅក្នុង**សៀវភៅកំណត់ត្រាតាមដានករណីបទល្មើស** ដែលជាឯកសារមូលដ្ឋានប្រើប្រាស់សម្រាប់គ្រប់គ្រងការងារធ្វើអធិការកិច្ច និងការអនុវត្តច្បាប់របស់អង្គភាព ដោយត្រូវកត់ត្រានូវព័ត៌មាននិងទិន្នន័យសំខាន់ៗតាមករណីបទល្មើសនីមួយៗ ចាប់ពីដំណាក់កាលធ្វើអធិការកិច្ចបឋម រហូតដល់ករណីបទល្មើសនីមួយៗ ត្រូវបានដោះស្រាយរួចជាស្ថាពរតាមនីតិវិធី។

## ជំពូកទី ៥
## វិធានការច្បាប់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

**ប្រការ ១៥.-**

រាល់ប្រតិបត្តិការរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ក្នុងការពិនិត្យបទល្មើស ត្រូវអនុវត្តតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម នីតិវិធីនៃប្រកាសនេះ និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

**ប្រការ ១៦.-**

ដោយផ្អែកតាមកម្រិតនៃភាពបដិលោមពីបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម ត្រូវអនុវត្តតាមវិធានការណាមួយក្នុងចំណោមវិធានការដូចខាងក្រោម៖

- ការចេញលិខិតឲ្យកែតម្រូវ
- ការចេញលិខិតព្រមាន
- ការចាត់វិធានការហាមឃាត់ជាបណ្តោះអាសន្នចំពោះការផ្គត់ផ្គង់ចែកចាយ ឬការចរាចរលើទីផ្សារនូវប្រភេទថ្នាំកសិកម្មនិងជីកសិកម្មទាំងឡាយណា ដែលក្រសួងបានស្រាវជ្រាវឃើញកស្តុតាងបង្ហាញហានិភ័យក្នុងផលិតកម្មកសិកម្ម ឬបង្កគ្រោះថ្នាក់ចំពោះសុខភាពមនុស្ស សត្វ និងបរិស្ថាន
- ការដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬឯកសារពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាតឬវិញ្ញាបនបត្រនោះប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម

- ការចាប់យកវត្ថុតាងនិងបិទស្លាកបោះត្រាលើវត្ថុតាង
- ការដកយកសំណាកថ្នាំកសិកម្មឬជីកសិកម្ម ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យនិងការធ្វើវិភាគផ្ទៀងផ្ទាត់បមាណីយ
- ការអនុវត្តនីតិវិធីពិន័យអន្តរការណ៍
- ការចងក្រងសំណុំរឿងនៃបទល្មើសដើម្បីបញ្ជូនទៅតុលាការ។

**ប្រការ ១៧.-**

នៅពេលបញ្ចប់ការងារអធិការកិច្ចនៅនឹងកន្លែង មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចមានសិទ្ធិចេញលិខិតឲ្យកែតម្រូវ ឬអាចធ្វើការកែតម្រូវដោយផ្ទាល់មាត់ ដល់ប្រតិបត្តិករថ្នាំកសិកម្មឬជីកសិកម្ម ចំពោះកំហុសផ្នែករដ្ឋបាលឬបច្ចេកទេសដែលប្រតិបត្តិករបានអនុវត្តច្បាប់មិនទាន់គ្រប់ជ្រុងជ្រោយ។

រាល់ការកែតម្រូវ ត្រូវបញ្ជាក់ឬចង្អុលបង្ហាញឲ្យច្បាស់លាស់នូវកំហុសរបស់ប្រតិបត្តិករ និងភាពបដិលោមពីការតម្រូវបមាណីយបច្ចេកទេស និងនីតិវិធីជាធរមានផ្សេងទៀតដើម្បីដាក់ចេញនូវវិធានការកែតម្រូវនៅក្នុងរយៈពេលមួយកំណត់ច្បាស់លាស់។ រាល់ការកែតម្រូវ ត្រូវចុះក្នុងកំណត់ហេតុត្រួតពិនិត្យកន្លែងកើតហេតុ ដើម្បីតាមដានការកែតម្រូវរបស់ប្រតិបត្តិករនៅពេលក្រោយ។

**ប្រការ ១៨.-**

នៅក្នុងដំណើរការអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ក្នុងករណីជួបបទល្មើសជាក់ស្តែង មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច មានសិទ្ធិដកហូតជាបណ្តោះអាសន្ន នូវវិញ្ញាបនបត្រ លិខិតអនុញ្ញាតគ្រប់ប្រភេទ ឬឯកសារដែលពាក់ព័ន្ធ ដកហូតយកសំណាកថ្នាំកសិកម្មឬជីកសិកម្មដើម្បីវិភាគផ្ទៀងផ្ទាត់បមាណីយ ចាប់យកវត្ថុតាងនិងបិទស្លាកបោះត្រាលើវត្ថុតាង និងចាត់វិធានការច្បាប់តាមនីតិវិធីជាធរមាន។

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសិទ្ធិចាត់វិធានការហាមឃាត់ជាបណ្តោះអាសន្ន មិនឲ្យធ្វើការផ្គត់ផ្គង់ចែកចាយឬចរាចរលើទីផ្សារនូវថ្នាំកសិកម្មឬជីកសិកម្មទាំងឡាយណា ដែលក្រសួងបានស្រាវជ្រាវឃើញភស្តុតាងបង្កហានិភ័យក្នុងផលិតកម្មកសិកម្ម ឬបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន។

នៅក្នុងដំណាក់កាលនៃការហាមឃាត់ជាបណ្តោះអាសន្ន ការដកហូត ឬការព្យួរវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតពាក់ព័ន្ធគ្រប់ប្រភេទ អ្នកកាន់កាប់វិញ្ញាបនបត្រឬលិខិតអនុញ្ញាតនោះមិនអាចធ្វើពាណិជ្ជកម្មឬប្រតិបត្តិការពាក់ព័ន្ធឡើយ ហើយថ្នាំកសិកម្មឬជីកសិកម្មនោះពុំអាចធ្វើចរាចរណ៍លើទីផ្សារបានឡើយ លើកលែងតែមានការប្រគល់ឲ្យវិញនៅក្រោយពេលបទល្មើសត្រូវបានដោះស្រាយ រួចជាស្ថាពរតាមនីតិវិធី។

## ប្រការ ១៩.-

ដោយផ្អែកតាមរបាយការណ៍អធិការកិច្ចរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម និង សំណុំរឿងនៃបទល្មើស ក្នុងរយៈពេលមិនលើសពី១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលរបាយការណ៍ ប្រធានអង្គភាពមានសមត្ថកិច្ចធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម មានសិទ្ធិចាត់វិធានការច្បាប់តាមនីតិវិធីជាធរមាន ឬស្នើសុំសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬសេចក្តីសម្រេចរបស់ប្រធានមន្ទីរកសិកម្មសាមី ដើម្បីបញ្ឈប់ប្រតិបត្តិការរបស់ជនប្រព្រឹត្តល្មើស ស្នើសុំដកហូត ឬព្យួរវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតដែលពាក់ព័ន្ធ។

ប្រធានអង្គភាពមានសមត្ថកិច្ចធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានផ្តល់សិទ្ធិឲ្យចេញលិខិតព្រមានជាលាយលក្សណ៍អក្សរ ចំពោះប្រតិបត្តិករថ្នាំកសិកម្មឬជីកសិកម្មដែលប្រព្រឹត្តល្មើសនឹងមាត្រា ១០៥ នៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

ប្រធានមន្ទីរកសិកម្មសាមី ត្រូវបានផ្តល់សិទ្ធិឲ្យចេញសេចក្តីសម្រេចដកហូត ឬព្យួរវិញ្ញាបនបត្រឬលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្មឬជីកសិកម្ម ដែលបានចេញដោយមន្ទីរកសិកម្ម ឬដោយការិយាល័យច្រកចេញចូលតែមួយនៃក្រុង ស្រុកសាមី។

## ប្រការ ២០.-

ប្រធានអង្គភាពមានសមត្ថកិច្ចធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសិទ្ធិចេញលិខិតកោះហៅឬសេចក្តីជូនដំណឹងដល់ប្រតិបត្តិករដែលប្រព្រឹត្តល្មើស ដើម្បីចូលខ្លួនមកកាន់អង្គភាពមានសមត្ថកិច្ច ធ្វើការដោះស្រាយបទល្មើសស្របតាមនីតិវិធី នៅក្នុងរយៈពេលកំណត់ជាក់លាក់។

ក្នុងករណីប្រតិបត្តិករឬជនប្រព្រឹត្តល្មើសនៅតែមិនបានចូលខ្លួនមកធ្វើការដោះស្រាយបទល្មើសតាមកាលកំណត់ក្នុងលិខិតកោះហៅឬសេចក្តីជូនដំណឹង ប្រធានអង្គភាពមានសមត្ថកិច្ចធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម មានសិទ្ធចាត់វិធានការច្បាប់បន្តតាមនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន។

គំរូសំណុំបែបបទសម្រាប់ការចាត់វិធានការច្បាប់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី២នៃប្រកាសនេះ។

## ប្រការ ២១.-

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសដូចមានចែងក្នុងមាត្រា១០៦ មាត្រា១០៧ និងមាត្រា១០៨ នៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម នៅពេលជនល្មើសសារភាពកំហុសនិងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍។

ក្នុងករណីជនល្មើសមិនសារភាពកំហុសនិងមិនយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវចងក្រងសំណុំរឿងនៃបទល្មើសពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្ម ដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី។

នីតិវិធីនិងសិទ្ធិពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ប្រការ ២២.-

ប្រតិបត្តិករថ្នាំកសិកម្មឬជីកសិកម្មណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច អាចធ្វើបណ្តឹងតវ៉ាក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃចេញវិធានការ ដើម្បីជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យសម្រេច។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចបង្កើតគណៈកម្មការស៊ើបអង្កេតមួយដើម្បីបើកការស្រាវជ្រាវនិងស៊ើបអង្កេតលើរាល់បណ្តឹងតវ៉ា។ បន្ទាប់ពីមានការស៊ើបអង្កេតច្បាស់លាស់លើករណីបណ្តឹងតវ៉ានោះរួច រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងតវ៉ានោះក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

ក្នុងករណីប្រតិបត្តិករនោះមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជននោះមានសិទ្ធិធ្វើបណ្តឹងទៅយន្តការផ្សេងទៀតរបស់រាជរដ្ឋាភិបាល ឬធ្វើបណ្តឹងទៅតុលាការតាមនីតិវិធី។

## ប្រការ ២៣.-

នៅក្នុងប្រតិបត្តិការអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ក្នុងករណីឆែកឆេរលំនៅឋាន គ្រឹះស្ថាន ឬមូលដ្ឋានធ្វើប្រតិបត្តិការដែលកើតមានបទល្មើសពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្ម មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវអនុវត្តវិធានការដូចខាងក្រោម៖

- ត្រូវស្នើសុំដីកាឲ្យឆែកឆេរពីសាលាដំបូងរាជធានី ខេត្តសាមី ឬត្រូវមានបញ្ជាផ្ទាល់ពីព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងសាមី។ ក្នុងករណីចាំបាច់ត្រូវមានវត្តមានរបស់ព្រះរាជអាជ្ញា ដើម្បីដឹកនាំនីតិវិធី និងត្រូវមានអាជ្ញាធរមូលដ្ឋាននៅកន្លែងកើតហេតុ ឬកម្លាំងប្រដាប់អាវុធចូលរួមតាមការចាំបាច់ ក្នុងប្រតិបត្តិការឆែកឆេរ
- ត្រូវប្រមូលនិងកត់ត្រាទុកជាបណ្តោះអាសន្ននូវវត្ថុតាងនិងភស្តុតាងផ្សេងទៀតនៅកន្លែងកើតមានបទល្មើស និងដកយកសំណាកថ្នាំកសិកម្មឬជីកសិកម្ម ដើម្បីធ្វើវិភាគ
- ត្រូវបំពេញសំណុំបែបបទនៃបទល្មើសនៅនឹងកន្លែងកើតហេតុឲ្យបានគ្រប់គ្រាន់តាមនីតិវិធី
- ក្នុងករណីមានការឃាត់ខ្លួនជនសង្ស័យ ការនាំខ្លួននិងបញ្ជូនសំណុំឯកសារឃាត់ខ្លួនជនសង្ស័យ ត្រូវប្រគល់ជូនព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ចសាមី ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

## ប្រការ ២៤.-

នៅពេលបញ្ចប់ប្រតិបត្តិការរបស់ខ្លួន មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវរៀបចំឯកសារនិងសំណុំបែបបទឲ្យបានគ្រប់គ្រាន់ និងត្រូវបំពេញសំណុំបែបបទបន្ថែមដែលពាក់ព័ន្ធ

រួមមាន៖ កំណត់ហេតុនៃបទល្មើស សាលាកបត្រទោសទណ្ឌ វិញ្ញាបនបត្របញ្ជាក់លទ្ធផលវិភាគសំណាកវត្ថុតាងថ្នាំកសិកម្មឬជីកសិកម្ម របាយការណ៍សំយោគ និងដីកាអមបញ្ជូន។

សំណុំបែបបទនៃបទល្មើសដែលត្រូវបញ្ជូនទៅតុលាការ ត្រូវមានការសម្រេចពីប្រធានអង្គភាពមានសមត្ថកិច្ចសាមី ឬពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈដីកាអមបញ្ជូនសំណុំរឿងនៃបទល្មើស។

**ប្រការ ២៥.-**

សំណាកថ្នាំកសិកម្មឬជីកសិកម្ម ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យឬជាវត្ថុតាងនៃបទល្មើសត្រូវបានដកយកដើម្បីធ្វើវិភាគ ដោយត្រូវរៀបចំជា៣(បី)សំណាក ក្នុង១យថាប្រភេទ។ កញ្ចប់សំណាកត្រូវបិទភ្ជិត ត្រូវមានស្លាកសម្គាល់ និងមានហត្ថលេខានៃមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ព្រះរាជអាជ្ញាឬតំណាង និងជនប្រព្រឹត្តល្មើសឬម្ចាស់វត្ថុតាង និងត្រូវចុះហត្ថលេខារួមលើកំណត់ហេតុដកយកគំរូសំណាក។

ការដកយកសំណាកថ្នាំកសិកម្មឬជីកសិកម្ម ត្រូវអនុវត្តតាមវិធានបច្ចេកទេសដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សំណាកថ្នាំកសិកម្មឬជីកសិកម្មដែលជាវត្ថុតាង ត្រូវតម្កល់ទុកនៅមន្ទីរកសិកម្មសាមីចំនួន១សំណាក បញ្ជូនមកនាយកដ្ឋាននីតិកម្មកសិកម្មចំនួន១សំណាក និងសម្រាប់ធ្វើវិភាគនៅមន្ទីរពិសោធន៍ចំនួន១សំណាក។

លទ្ធផលវិភាគគំរូសំណាកថ្នាំកសិកម្មឬជីកសិកម្ម ត្រូវបញ្ជូនទៅអង្គភាពអធិការកិច្ចមានសមត្ថកិច្ចសាមីវិញ ដើម្បីភ្ជាប់ជាមួយសំណុំរឿងនៃបទល្មើស ឬត្រូវបញ្ជូនទៅព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តសាមីវិញ ក្នុងករណីសំណុំរឿងនៃបទល្មើសត្រូវបានបញ្ជូនទៅតុលាការរួច។

**ប្រការ ២៦.-**

វត្ថុតាងល្មើសដែលត្រូវចាប់យកក្នុងប្រតិបត្តិការអធិការកិច្ចត្រូវរក្សាទុកក្នុងបន្ទប់ឬឃ្លាំងដែលជានាសន្តិសុខនិងសុវត្ថិភាព គំនរវត្ថុតាងត្រូវបិទស្លាកបោះត្រា ឬគូសខ្វែងសម្គាល់ សោរទ្វារឃ្លាំងរក្សាវត្ថុតាងត្រូវបិទភ្ជិតដោយក្រដាសសុវត្ថិភាព ដែលហាមឃាត់ការប៉ះពាល់រហូតដល់ករណីបទល្មើសត្រូវបានដោះស្រាយចប់តាមនីតិវិធី ឬតាមរយៈការអនុវត្តសាលក្រមឬសាលដីកាស្ថាពររបស់តុលាការ។

ក្នុងករណីអត្តសញ្ញាណម្ចាស់វត្ថុតាងនៃបទល្មើសមិនត្រូវបានស្គាល់ អង្គភាពមានសមត្ថកិច្ចធ្វើអធិការកិច្ចសាមី ត្រូវចេញសេចក្ដីជូនដំណឹងរកជនល្មើសឬម្ចាស់វត្ថុតាងនៃបទល្មើស ដើម្បីចូលខ្លួនមកដោះស្រាយតាមនីតិវិធីជាធរមាន ក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃធ្វើអធិការកិច្ច និងចាប់យកវត្ថុតាងនោះ។

**ប្រការ ២៧.-**

ក្នុងករណីដែលវត្ថុតាងនៃបទល្មើសជាផលិតផលហាមឃាត់ ឬបង្កគ្រោះថ្នាក់ចំពោះសុខភាពមនុស្ស សត្វ និងបរិស្ថាន មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម មានសិទ្ធិចាប់យកនិងបិទស្លាក បោះត្រាលើវត្ថុតាងពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្ម ដោយស្នើសុំដីកាសម្រេចរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តសាមី ដើម្បីធ្វើការបំផ្លាញចោល ដោយអនុលោមតាមនីតិវិធីជាធរមាន។

**ប្រការ ២៨.-**

ការឆែកឆេរ ការឃាត់ខ្លួនជនល្មើស ការចាត់វិធានការលើវត្ថុតាងល្មើស និងប្រតិបត្តិការពាក់ព័ន្ធបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

គំរូសំណុំបែបបទប្រើប្រាស់ក្នុងការត្រួតពិនិត្យនិងដោះស្រាយបទល្មើសនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់ដោយប្រកាសរួមដោយឡែករបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ ចំពោះមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**ប្រការ ២៩.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនិងនីតិវិធីដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មជាក់លាក់ ដោយអនុលោមតាមទោសប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ៣០.-**

ប្រកាសឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

## ប្រការ ៣១.-

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

ច័ន្ទ.សារុន

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ ៣១
-ឯកសារ កាលប្បវត្តិ

# គំរូលិខិតបញ្ជាបេសកកម្ម និងសេចក្តីជូនដំណឹងស្តីពីការធ្វើអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម

## ក- គំរូលិខិតបញ្ជាបេសកកម្មអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**លេខ កសក**

### លិខិតបញ្ជាបេសកកម្មអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម (ក)

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម

-បានឃើញប្រកាសលេខ..........................ប្រក.កសក ចុះថ្ងៃទី.........ខែ...........ឆ្នាំ...............ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្ម និង ជីកសិកម្ម

-តាមសំណើរបស់នាយកដ្ឋាននីតិកម្មកសិកម្មលេខ..........................ននក ចុះថ្ងៃទី.........ខែ...............ឆ្នាំ................

### សម្រេច

**ចាត់តាំងមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មដែលមានសមាសភាពដូចខាងក្រោម៖**

១-លោក.............................................ឋានៈ.....................................................ជាប្រធាន

២-លោក.............................................ឋានៈ.....................................................ជាសមាជិក

៣-លោក.............................................ឋានៈ.....................................................ជាសមាជិក

.........................................................................................................................។

**ចុះបំពេញបេសកកម្ម** ៖ នៅរាជធានី ខេត្ត.........................................................................។

**គោលបំណង** ៖ ធ្វើអធិការកិច្ច.........................................................................
.................................................................................................។

**មធ្យោបាយធ្វើដំណើរ** ៖ .................................................................................
.................................................................................................។

**ចេញដំណើរ** ៖ ថ្ងៃទី........ខែ.............. ឆ្នាំ.......................។

**ត្រឡប់មកដល់វិញ** ៖ ថ្ងៃទី........ខែ.............. ឆ្នាំ.......................។

អាស្រ័យហេតុនេះ សូមអង្គភាពមានសមត្ថកិច្ចជួយសម្រួលបេសកកម្មនេះឲ្យបានសម្រេចតាមការគួរ។

រាជធានីភ្នំពេញ, ថ្ងៃទី...........ខែ.............ឆ្នាំ...........

**រដ្ឋមន្ត្រី**

**ចម្លងជូន**
-សាលារាជធានី ខេត្ត..............
"ដើម្បីជូនជ្រាប"
-នាយកដ្ឋាននីតិកម្មកសិកម្ម
-មន្ទីរកសិកម្មរាជធានី ខេត្ត........
"ដើម្បីមុខការនិងសហការ"
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មន្ទីរកសិកម្មរាជធានី ខេត្ត.................
លេខ មក

# លិខិតបញ្ជាបេសកកម្មអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម(៤)

## ប្រធានមន្ទីរកសិកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម
-បានឃើញប្រកាសលេខ..........................ប្រក.កសក ចុះថ្ងៃទី.........ខែ...........ឆ្នាំ...............ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្ម និង ជីកសិកម្ម
-តាមសំណើរបស់ការិយាល័យនីតិកម្មកសិកម្មលេខ.........................កនក ចុះថ្ងៃទី.........ខែ...............ឆ្នាំ................

## សម្រេច

**ចាត់តាំងមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មដែលមានសមាសភាពដូចខាងក្រោម៖**

១-លោក.............................................ឋានៈ........................................................ជាប្រធាន
២-លោក.............................................ឋានៈ........................................................ជាសមាជិក
៣-លោក.............................................ឋានៈ........................................................ជាសមាជិក
..........................................................................................................................។

**ចុះបំពេញបេសកកម្ម** : នៅស្រុក ក្រុង..........................................................................។
**ក្នុងគោលបំណង** : ធ្វើអធិការកិច្ច..........................................................................
..........................................................................................។
**មធ្យោបាយធ្វើដំណើរ** : ..........................................................................................
..........................................................................................។
**ចេញដំណើរ** : ថ្ងៃទី........ខែ............... ឆ្នាំ........................។
**ត្រឡប់មកដល់វិញ** : ថ្ងៃទី........ខែ............... ឆ្នាំ........................។

អាស្រ័យហេតុនេះ សូមអង្គភាពមានសមត្ថកិច្ចជួយសម្រួលបេសកកម្មនេះឱ្យបានសម្រេចតាមការគួរ។

......................., ថ្ងៃទី..........ខែ.............ឆ្នាំ.............
**ប្រធានមន្ទីរ**

**ចម្លងជូន**
-សាលាស្រុក ក្រុង.............
-នាយកដ្ឋាននីតិកម្មកសិកម្ម
"ដើម្បីជូនជ្រាប"
-ការិយាល័យនីតិកម្មកសិកម្មរាជធានី ខេត្ត............
-ការិយាល័យកសិកម្មស្រុក ក្រុង..........................
"ដើម្បីមុខការនិងសហការ"
-ឯកសារ កាលប្បវត្តិ

១- គំរូសេចក្តីជូនដំណឹងស្តីពីការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋាននីតិកម្មកសិកម្ម

លេខ នធក

# សេចក្តីជូនដំណឹង

## ស្តីពីការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម(១)

## ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម

-បានឃើញប្រកាសលេខ.........................ប្រក.កសក ចុះថ្ងៃទី.......ខែ...........ឆ្នាំ...............ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ច ថ្នាំកសិកម្មនិងជីកសិកម្ម

## ជម្រាបមក

លោក លោកស្រី.......................................ឋាន:........................................................
នៃក្រុមហ៊ុន........................................................................... មេត្តាជ្រាបថា ដោយអនុលោមតាមលិខិតបញ្ជាបេសកកម្មលេខ.....................កសក ចុះថ្ងៃទី...........ខែ................ឆ្នាំ.................
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចាត់តាំងមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ដើម្បីធ្វើអធិការកិច្ចលើប្រតិបត្តិការពាក់ព័ន្ធនឹងថ្នាំកសិកម្មនិងជីកសិកម្ម ដែលអនុវត្តចំពោះក្រុមហ៊ុនឬគ្រឹះស្ថានរបស់លោក លោកស្រីចាប់ពីថ្ងៃទី........ ខែ..............ឆ្នាំ............... ដល់ថ្ងៃទី.....................
ខែ....................ឆ្នាំ................។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រី មេត្តាជ្រាបជាព័ត៌មាន និងត្រៀមឯកសារពាក់ព័ន្ធ ព្រមទាំងបង្កលក្ខណៈសហការក្នុងប្រតិបត្តិការអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច តាមកាលបរិច្ឆេទកំណត់ខាងលើ ជាចាំបាច់។

រាជធានីភ្នំពេញ, ថ្ងៃទី...........ខែ.............ឆ្នាំ...........

**ប្រធាននាយកដ្ឋាន**

**ចម្លងជូន:**
-សាលារាជធានី ខេត្ត.............
-មន្ទីរកសិកម្មរាជធានី ខេត្ត
"ដើម្បីជូនជ្រាប"
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មន្ទីរកសិកម្មរាជធានី ខេត្ត.......

លេខ មក/កនក

# សេចក្តីជូនដំណឹង
## ស្តីពីការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម(២)

## ប្រធានមន្ទីរកសិកម្មខេត្ត.......................

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
-បានឃើញប្រកាសលេខ...........................ប្រក.កសក ចុះថ្ងៃទី.......ខែ...........ឆ្នាំ...............ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម
-យោងលិខិតបញ្ជាបេសកកម្មអធិការកិច្ចលេខ............................កសក ចុះថ្ងៃទី...........ខែ.................ឆ្នាំ...........របស់មន្ទីរកសិកម្ម

## ជម្រាបមក

លោក លោកស្រី........................................ជាពាណិជ្ជករ ប្រតិបត្តិករថ្នាំកសិកម្មនិងជីកសិកម្មនៅក្នុងរាជធានី ខេត្ត..............................មេត្តាជ្រាបថា ដោយអនុលោមតាមលិខិតបញ្ជាបេសកកម្មលេខ...............កសក ចុះថ្ងៃទី......ខែ............ឆ្នាំ.........មន្ទីរកសិកម្មខេត្ត........................ បានចាត់តាំងមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ដើម្បីធ្វើអធិការកិច្ចលើប្រតិបត្តិការពាក់ព័ន្ធនឹងថ្នាំកសិកម្មនិងជីកសិកម្ម ដែលអនុវត្តចំពោះក្រុមហ៊ុនឬគ្រឹះស្ថានរបស់លោក លោកស្រីចាប់ពីថ្ងៃទី............ខែ..............ឆ្នាំ............... ដល់ថ្ងៃទី..........ខែ...................ឆ្នាំ...............។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រី មេត្តាជ្រាបជាព័ត៌មាន និងត្រៀមឯកសារពាក់ព័ន្ធ ព្រមទាំងបង្កលក្ខណៈសហការក្នុងប្រតិបត្តិការអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច នៅក្នុងកាលបរិច្ឆេទខាងលើ ជាចាំបាច់។

រាជធានីភ្នំពេញ, ថ្ងៃទី...........ខែ.............ឆ្នាំ...........
**ប្រធានការិយាល័យ**

**ចម្លងជូន៖**
-សាលារាជធានី ខេត្ត..................
-សាលាស្រុក ក្រុង......................
"ដើម្បីជូនជ្រាប"
-ឯកសារ កាលប្បវត្តិ

ឧបសម្ពន្ធទី២ នៃប្រកាសលេខ..១៧៦........ប្រក.កសក ចុះថ្ងៃទី១៤...ខែធ្នូឆ្នាំ២០១៣.
ស្តីពី"នីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម"

**គំរូសំណុំបែបបទសម្រាប់ចាត់វិធានការច្បាប់**
**របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម**

## ក- គំរូលិខិតឲ្យកែតម្រូវ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**នាយកដ្ឋាននីតិកម្មកសិកម្ម/**
**មន្ទីរកសិកម្មរាជធានី ខេត្ត.........**

**លេខ**

# លិខិតឲ្យកែតម្រូវ

**យើង...............................................................................**
**ជាមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម

-បានឃើញប្រកាសលេខ...........................ប្រក.កសក ចុះថ្ងៃទី.......ខែ...........ឆ្នាំ...........ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

-យោងលទ្ធផលត្រួតពិនិត្យកន្លែងកើតហេតុ ចុះថ្ងៃទី...........ខែ...............ឆ្នាំ................

**សម្រេច**

ឲ្យឈ្មោះ.................................................ភេទ..............អាយុ...................ឆ្នាំ សញ្ជាតិ................
មុខរបរ...............................................................................................................................
ដែលមានអាសយដ្ឋានធ្វើប្រតិបត្តិការថ្នាំកសិកម្មនិងជីកសិកម្មនៅគ្រឹះស្ថានលេខ........ ផ្លូវ......... ភូមិ..................
ឃុំ/សង្កាត់.......................... ក្រុង/ស្រុក/ខណ្ឌ............................ រាជធានី/ខេត្ត...................................
ឲ្យធ្វើការកែតម្រូវនូវកំហុសរដ្ឋបាលនិងបច្ចេកទេសមួយចំនួនឲ្យស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មដូចខាងក្រោម៖

.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................

ឈ្មោះ..........................ត្រូវកែតម្រូវនូវកំហុសខាងលើ ក្នុងរយៈពេល....................ថ្ងៃ គិតចាប់ពីថ្ងៃចេញលិខិតកែតម្រូវនេះតទៅ។

ក្នុងករណីសាមីខ្លួនមិនព្រមកែតម្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងអនុវត្តវិធានការច្បាប់តាមនីតិវិធីបន្ត។

......................., ថ្ងៃទី...........ខែ..............ឆ្នាំ..........

**មន្ត្រីអធិការកិច្ច**

១- គំរូលិខិតព្រមាន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**នាយកដ្ឋាននីតិកម្មកសិកម្ម**

**លេខ** **នឧក**

# លិខិតព្រមាន(១)

## ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម

-បានឃើញប្រកាសលេខ..........................ប្រក.កសក ចុះថ្ងៃទី.......ខែ...........ឆ្នាំ...........ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

-យោងតាមរបាយការណ៍ធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ចុះថ្ងៃទី..........ខែ..............ឆ្នាំ............របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

## សម្រេច

ធ្វើការព្រមានចំពោះឈ្មោះ........................................ភេទ.............អាយុ..........ឆ្នាំ សញ្ជាតិ............
មុខរបរ.....................................................................................................................................
ដែលមានអាសយដ្ឋានធ្វើប្រតិបត្តិការថ្នាំកសិកម្មនិងជីកសិកម្មនៅគ្រឹះស្ថានលេខ........ ផ្លូវ....... ភូមិ...................
ឃុំ/សង្កាត់....................... ក្រុង/ស្រុក/ខណ្ឌ.......................... រាជធានី/ខេត្ត.........................................
ដែលបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មដូចខាងក្រោម៖
.....................................................................................................................................
.....................................................................................................................................
.....................................................................................................................................
.....................................................................................................................................
.....................................................................................................................................
.....................................................................................................................................
.....................................................................................................................................
.....................................................................................................................................

ឈ្មោះ.................................... ត្រូវបញ្ឈប់អំពើល្មើសដែលខ្លួនបានប្រព្រឹត្ត និងត្រូវអនុវត្តតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ក្នុងរយៈពេល...................ថ្ងៃ គិតចាប់ពីថ្ងៃចេញលិខិតព្រមាននេះតទៅ។ ក្នុងករណីសាមីខ្លួន មិនបញ្ឈប់អំពើល្មើសខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងចាត់វិធានការចងក្រងសំណុំរឿង ដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី។

រាជធានីភ្នំពេញ, ថ្ងៃទី...........ខែ.............ឆ្នាំ........

**ប្រធាននាយកដ្ឋាន**

**ចម្លងជូន**
-មន្ទីរកសិកម្មរាជធានី ខេត្ត............
"ដើម្បីមុខការ"
-សាលារាជធានី ខេត្ត...................
-សមត្ថកិច្ចពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មន្ទីរកសិកម្មរាជធានី ខេត្ត...............

លេខ មក

# លិខិតព្រមាន(២)

## ប្រធានមន្ទីរកសិកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម

-បានឃើញប្រកាសលេខ..............................ប្រក.កសក ចុះថ្ងៃទី.......ខែ...........ឆ្នាំ...............ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

-យោងតាមរបាយការណ៍ធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ចុះថ្ងៃទី..........ខែ..............ឆ្នាំ............របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

## សម្រេច

ធ្វើការព្រមានចំពោះឈ្មោះ.......................................ភេទ.............អាយុ..........ឆ្នាំ សញ្ជាតិ............
មុខរបរ..................................................................................................................................
ដែលមានអាសយដ្ឋានធ្វើប្រតិបត្តិការថ្នាំកសិកម្មនិងជីកសិកម្មនៅគ្រឹះស្ថានលេខ........ ផ្លូវ....... ភូមិ...................
ឃុំ/សង្កាត់....................... ក្រុង/ស្រុក/ខណ្ឌ........................... រាជធានី/ខេត្ត..........................................
ដែលបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មដូចខាងក្រោម៖
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

ឈ្មោះ.................................... ត្រូវបញ្ឈប់អំពើល្មើសដែលខ្លួនបានប្រព្រឹត្ត និងត្រូវអនុវត្តតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ក្នុងរយៈពេល...................ថ្ងៃ គិតចាប់ពីថ្ងៃចេញលិខិតព្រមាននេះតទៅ។ ក្នុងករណីសាមីខ្លួន មិនបញ្ឈប់អំពើល្មើសខាងលើ មន្ទីរកសិកម្មនឹងចាត់វិធានការចងក្រងសំណុំរឿង ដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី។

........................, ថ្ងៃទី...........ខែ.............ឆ្នាំ...........

**ប្រធានមន្ទីរ**

**ចម្លងជូន៖**
-នាយកដ្ឋាននីតិកម្មកសិកម្ម
-សាលារាជធានី ខេត្ត...................
-សមត្ថកិច្ចពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-ការិយាល័យនីតិកម្មកសិកម្ម
"ដើម្បីមុខការ"
-ឯកសារ កាលប្បវត្តិ

## ក- គំរូសេចក្តីសម្រេចដកហូតឬព្យួរវិញ្ញាបនបត្រឬលិខិតអនុញ្ញាត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**លេខ ................ កសក**

# សេចក្តីសម្រេច

# ដកហូតឬព្យួរវិញ្ញាបនបត្រឬលិខិតអនុញ្ញាត(១)

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម

-បានឃើញប្រកាសលេខ............................ប្រក.កសក ចុះថ្ងៃទី.......ខែ............ឆ្នាំ...........ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

-យោងកំណត់ហេតុនិងរបាយការណ៍ធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មចុះថ្ងៃទី..........ខែ..................ឆ្នាំ..............របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

## សម្រេច

☐ដកហូត ☐ព្យួរ វិញ្ញាបនបត្រឬលិខិតអនុញ្ញាតលេខ..............................កសក ចុះថ្ងៃទី........ ខែ..................ឆ្នាំ.....................ដែលកាន់កាប់ដោយក្រុមហ៊ុន ប្រតិបត្តិករ....................................... ដែលមានអាសយដ្ឋានប្រតិបត្តិការថ្នាំកសិកម្មនិងជីកសិកម្មនៅគ្រឹះស្ថានលេខ................ ផ្លូវ.............. ភូមិ......................... ឃុំ សង្កាត់............................... ក្រុង ស្រុក ខណ្ឌ.................................... រាជធានី ខេត្ត...................................................។

ក្រុមហ៊ុន ប្រតិបត្តិករ................................................ខាងលើ ត្រូវបញ្ឈប់សកម្មភាពប្រតិបត្តិការពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្ម ក្នុងរយៈពេល០៣(បី)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចដកហូតឬព្យួរនេះតទៅ។ ក្នុងករណីក្រុមហ៊ុននៅតែបន្តសកម្មភាពប្រតិបត្តិការពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្មទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងចាត់វិធានការតាមច្បាប់ជាធរមាន។

រាជធានីភ្នំពេញ, ថ្ងៃទី...........ខែ............ឆ្នាំ............

**រដ្ឋមន្ត្រី**

**ចម្លងជូន៖**

-សាលារាជធានី ខេត្ត...........
"ដើម្បីជូនជ្រាប"
-នាយកដ្ឋាននីតិកម្មកសិកម្ម
-មន្ទីរកសិកម្មរាជធានី ខេត្ត.............
"ដើម្បីមុខការ និងសហការ"
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មន្ទីរកសិកម្មរាជធានី ខេត្ត........
លេខ មក

# សេចក្តីសម្រេច
# ដកហូតឬព្យួរវិញ្ញាបនបត្រឬលិខិតអនុញ្ញាត(២)

## ប្រធានមន្ទីរកសិកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
-បានឃើញប្រកាសលេខ............................ប្រក.កសក ចុះថ្ងៃទី.......ខែ............ឆ្នាំ............ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម
-យោងកំណត់ហេតុនិងរបាយការណ៍ធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មចុះថ្ងៃទី..........ខែ.................ឆ្នាំ.............របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

## សម្រេច

☐ដកហូត ☐ព្យួរ វិញ្ញាបនបត្រឬលិខិតអនុញ្ញាតលេខ...............................កសក ចុះថ្ងៃទី........ ខែ.................ឆ្នាំ....................ដែលកាន់កាប់ដោយក្រុមហ៊ុន ប្រតិបត្តិករ.................................... ដែលមានអាសយដ្ឋានប្រតិបត្តិការថ្នាំកសិកម្មនិងជីកសិកម្មនៅគ្រឹះស្ថានលេខ................ ផ្លូវ............... ភូមិ......................... ឃុំ សង្កាត់.............................. ក្រុង ស្រុក ខណ្ឌ.................................. រាជធានី ខេត្ត.......................................................។

ក្រុមហ៊ុន ប្រតិបត្តិករ..........................................ខាងលើ ត្រូវបញ្ឈប់សកម្មភាពប្រតិបត្តិការពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្ម ក្នុងរយះពេល០៣(បី)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចដកហូតឬព្យួរនេះតទៅ។ ក្នុងករណីក្រុមហ៊ុននៅតែបន្តសកម្មភាពប្រតិបត្តិការពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្មទៀត មន្ទីរកសិកម្ម នឹងចាត់វិធានការតាមច្បាប់ជាធរមាន។

...................., ថ្ងៃទី...........ខែ............ឆ្នាំ...........

**ប្រធានមន្ទីរកសិកម្ម**

**ចម្លងជូនៈ**
-នាយកដ្ឋាននីតិកម្មកសិកម្ម
-សាលារាជធានី ខេត្ត............
-សាលាស្រុក ក្រុង...............
"ដើម្បីជូនជ្រាប"
-ការិយាល័យនីតិកម្មកសិកម្ម
"ដើម្បីមុខការ"
-ឯកសារ កាលប្បវត្តិ